Empowered lives.
Resilient nations.

# ព្រឹត្តិបត្រព័ត៌មាន

លេខ ៤៥
ខែ មីនា ឆ្នាំ ២០១៥

*យូអិនឌីភី ធ្វើដៃគូជាមួយប្រជាជនគ្រប់ស្រទាប់សង្គមក្នុងការជួយប្រជាជាតិឲ្យមានភាពស្ថិតស្ថាញទប់ទល់នឹងវិបត្តិ ជំរុញ និងរក្សាចីរភាព កំណើន សំដៅលើកស្ទួយគុណភាពនៃជីវភាពសម្រាប់ទាំងអស់គ្នា។ យើងមានវត្តមានក្នុងប្រទេសនិងដែនដីជាង ១៧០ ហើយយើងប្រើប្រាស់ទស្សនវិស័យសកល និងក្នុងស្រុក ដើម្បីជួយប្រជាជន និងប្រជាជាតិកសាងជីវភាពឲ្យបានកាន់តែប្រសើរ និងរឹងមាំថែមទៀត។*

## ការស្តារឡើងវិញក្រោយទឹកជំនន់សម្រាលការលំបាករបស់អ្នកជនបទ

កម្ពុជាបានរងការប៉ះទង្គិចដោយទឹកជំនន់នៅឆ្នាំ ២០១៣។ការធ្លាក់ភ្លៀងខ្លាំងរួមផ្សំជាមួយជំនន់នៃទឹកទន្លេមេគង្គ បានបង្កការខូចខាតជាច្រើនចំពោះហេដ្ឋារចនាសម្ព័ន្ធ និងដំណាំ ដែលរំខានរបរចិញ្ចឹមជីវិតរបស់ជនកម្ពុជាក្រីក្រនៅតាម ទីជនបទ។

លោក ចាន់ ម៉ន ដែលរស់នៅក្នុងភូមិថ្លុង ជាកន្លែងងាយរងការជន់លិចមួយក្នុងខេត្តសៀមរាប នៅភាគពាយព្យនៃប្រទេសកម្ពុជា បានពោលថា “វាជាការលំបាកសម្រាប់ខ្ញុំដើម្បីធ្វើដំណើរទៅពេទ្យស្រុក និងសម្រាប់អ្នកភូមិទាំងអស់ដើម្បីទៅរកទិញស្បៀងអាហារដោយសារផ្លូវខូចខាតបណ្តាលពីទឹកជំនន់”។

បុរសអាយុ ៨០ឆ្នាំ បានរម្លឹកឡើងវិញផងដែរថា គាត់ត្រូវធ្វើដំណើរជិតមួយម៉ោងពីភូមិនេះ ទៅមន្ទីរពេទ្យស្រុក ដែលស្ថិតនៅចម្ងាយប្រហែល ២០គ.ម ពីគ្នា។ ឥឡូវនេះការធ្វើដំណើរនេះចំណាយពេលត្រឹមតែកន្លះម៉ោងប៉ុណ្ណោះ បន្ទាប់ពីផ្លូវត្រូវបានជួសជុលឡើងវិញដោយប្រើមូលនិធិគម្រោងស្តារហេដ្ឋារចនាសម្ព័ន្ធក្រោយទឹកជំនន់ពីដៃគូអភិវឌ្ឍន៍នានា។ គម្រោងទាំងនេះបានអនុវត្តបន្ទាប់ពីការបញ្ចេញរបាយការណ៍វាយតម្លៃតម្រូវការនៅដំណាក់កាលដំបូងក្រោយជំនន់ ដោយយូអិនឌីភី កាលពីខែមេសា ឆ្នាំ ២០១៤។

ទឹកជំនន់នេះបានបង្កការបាត់បង់ជីវិតមនុស្សចំនួន ១៦៨នាក់ដែលភាគច្រើនជាកុមារ។ជំនន់បានបន្សល់ទុកនូវមហន្តរាយជាច្រើននៅទូទាំងខេត្តចំនួន ២០។ ស្រូវនៅលើផ្ទៃដីជាច្រើនពាន់ហិកតាត្រូវបានបំផ្លាញ ហើយផ្លូវជនបទជាច្រើនរយគីឡូម៉ែត្រដែលមាននាទីយ៉ាងសំខាន់ក្នុងការទ្រទ្រង់សេដ្ឋកិច្ចសម្រាប់ជនក្រីក្រនៅជនបទត្រូវបានបំផ្លាញ។

តទៅទំព័រទី ២

## មាតិកា

កម្មវិធីពហុព័ត៌មានពិភាក្សាបញ្ហាការងាររបស់យុវជនកម្ពុជា ..................................៣
កម្មវិធីប្រែប្រួលអាកាសធាតុនៅកម្ពុជាបានទទួលការគាំទ្របន្តពីសហភាពអឺរ៉ុប ស៊ុយអែដ និងយូអិនឌីភី ..៤
ប្រតិភូឡាវធ្វើទស្សនកិច្ចសិក្សាអំពីកសិកម្មបន្សាំការប្រែប្រួលអាកាសធាតុ ...................... ៥
ផ្ទៃដីសម្អាតមីនរួចបន្ថែមទៀតត្រូវបានប្រគល់ជូនកសិករ ........................................ ៥
វិនិយោគលើមូលធនមនុស្សដើម្បីចីរភាពកំណើនពេលអនាគត.................................. ៦

## ពង្រីកការបន្សាំនឹងអាកាសធាតុតាមរយៈការរៀបចំផែនការនៅថ្នាក់ក្រោមជាតិ



Photo: UNDP Cambodia

*អ្នកលក់ម្ហូបម្នាក់កំពុងថ្លឹងសាច់នៅលើផ្លូវជនបទមួយក្នុងខេត្តបាត់ដំបង។ ផ្លូវនេះស្ថិតក្នុងខ្សែផ្លូវប្រវែង 4.5 គីឡូម៉ែត្រក្នុងឃុំបីនៅបាត់ដំបង ដែលត្រូវបានស្តារឲ្យខ្ពស់ងាយស្រួលសម្រាប់អ្នកស្រុកប្រើប្រាស់ក្នុងរដូវទឹកជំនន់។ ក្រុមប្រឹក្សាឃុំជាអ្នកអនុវត្តន៍គម្រោងស្តារផ្លូវនេះ ដោយមានការឧបត្ថម្ភមូលនិធីបន្សាំការប្រែប្រួលអាកាសធាតុតាមរយៈ UNDP។*

ចូរស្រមៃមើលបន្តិចអំពីការរស់នៅក្នុងភូមិមួយដែលប្រឈមនឹងការខ្វះខាតទឹកធ្ងន់ធ្ងរ យ៉ាងហោចណាស់រយៈពេលប្រាំខែក្នុងមួយឆ្នាំ។ ដើម្បីរស់នៅបាន អ្នកភូមិត្រូវធ្វើដំណើរទៅមកលើផ្លូវចម្ងាយប្រាំមួយគីឡូម៉ែត្រក្នុងមួយថ្ងៃ ដើម្បីដងទឹកមកពីស្រះសិប្បនិម្មិតមួយដែលបានកើតឡើងដោយសារក្រុមហ៊ុនសាងសង់បានជីកយកដីទៅធ្វើផ្លូវតែប៉ុណ្ណោះ។

មេភូមិឈ្មោះ ចាន់ ស៊ា អាយុ ៥៧ឆ្នាំ បានពោលថា “មុននឹងមានស្រះនោះ អ្នកភូមិយើងត្រូវចំណាយពេលយ៉ាងហោចណាស់ប្រាំម៉ោងក្នុងមួយថ្ងៃ ដើម្បីស្វែងរកទឹកពីកន្លែងឆ្ងាយៗ។ នៅក្នុងភូមិនេះមានអណ្តូងស្នប់តែបីប៉ុណ្ណោះ ប៉ុន្តែ អណ្តូងទាំងនោះរីងស្ងួតនៅរដូវប្រាំង។ អ្នកភូមិត្រូវក្រោកពីព្រលឹមនៅម៉ោង ៤ភ្លឺ ដើម្បីមករកទឹកនៅអណ្តូងស្នប់នេះ ហើយជាញឹកញាប់ពួកគេទាស់ទែងគ្នា អំពីអ្នកណាត្រូវបានទឹកមុនគេ”។

នៅពេលត្រូវចំណាយពេលប្រាំម៉ោងដើម្បីគ្រាន់តែបានទឹកសម្រាប់ចំអិនអាហារ និងលាងសំអាតពួកគេពុំមានពេលនៅសល់ច្រើនឡើយ ដើម្បីតថភាពគ្រួសារណាមួយក្នុងការរកចំណូលសម្រាប់ចិញ្ចឹមជីវិត។ នេះជាឃុំថ្មីដ៏លំបាកដែលប្រជាជនចំនួន ៣៨០ នាក់ នៅក្នុងភូមិដាន នៃស្រុកគូលែន ខេត្តព្រះវិហារ បានស៊ូទ្រាំអស់ពេលជាយូរមកហើយ។

ប៉ុន្តែថ្មីៗនេះស្រះជីកថ្មីមួយនៅក្រោយភូមិអាចជួយកាត់បន្ថយស្ថានភាពដ៏លំបាកនេះ បើទោះជាវាមិនអាចលុបបំបាត់ការលំបាកទាំងស្រុងក្តី។

ស្រះនេះដែលមានជម្រៅបីម៉ែត្រ និងទំហំ ១.៦៥០ ម៉ែត្រការ៉េ ត្រូវបានសាងសង់ជាផ្នែកមួយនៃអន្តរាគមន៍តាមរយៈដំណើរការរៀបចំផែនការអភិវឌ្ឍន៍នៅមូលដ្ឋានក្នុងប្រទេសកម្ពុជា ដើម្បីកាត់បន្ថយភាពងាយរងគ្រោះរបស់សហគមន៍ ជនបទនៅកម្ពុជាចំពោះមុខការប្រែប្រួលអាកាសធាតុ។ នៅក្នុងវិធានការពង្រីកសកម្មភាពគម្រោងទាំងនេះបានពង្រឹងជាបន្ថែមនូវកិច្ចផ្តួចផ្តើមប្រកបដោយជោគជ័យកន្លងមកនៅក្រោមគម្រោងដទៃទៀត ដែលធ្វើការកែលម្អរបរចិញ្ចឹមជីវិតដែលធន់នឹងអាកាសធាតុតាមរយៈវិធីនានាមួយចំនួន ដូចជា ការស្តារហេដ្ឋារចនាសម្ព័ន្ធ និងការណែនាំអំពីកសិកម្មចម្រុះ ដើម្បីជួយអ្នកភូមិបង្កើនប្រាក់ចំណូលប្រចាំគ្រួសារ និងការសន្សំសំចៃសម្រាប់ពេលប្រជុំជន។

ចាន់ ស៊ា ប្រធានភូមិដាន បានពោលថា “ស្រះថ្មីនៅក្រោយភូមិយើងនេះនឹងជួយសម្រាលបន្ទុកយ៉ាងច្រើនសម្រាប់ប្រជាជនយើង ជាពិសេស ស្ត្រីដែលត្រូវរ៉ាប់រងការទទួលខុសត្រូវក្នុងការស្វែងរកទឹកនៅពេលដែលប្តីត្រូវធ្វើការនៅឆ្ងាយពីផ្ទះដើម្បីរកលុយចញ្ចឹមគ្រួសារ”។

តទៅទំព័រទី ២

# ពង្រីកការបន្សាំនឹងអាកាសធាតុតាមរយៈការរៀបចំផែនការនៅថ្នាក់ក្រោមជាតិ

*តមកពីទំព័រទី ១*

មកដល់ពេលនេះ ឃុំចំនួន ៣២ នៅទូទាំងស្រុកចំនួនប្រាំនៃខេត្តតាកែវ បាត់ដំបង និងព្រះវិហារ បានរួមបញ្ចូលការប្រែប្រួលអាកាសធាតុ និងការបន្សាំទៅក្នុងកម្មវិធីវិនិយោគថ្នាក់ស្រុក និងឃុំ។ ក្នុងចំណោមឃុំទាំងនោះ កម្មវិធីហេដ្ឋារចនាសម្ព័ន្ធចំនួន ១៧ និងមិនមែនហេដ្ឋារចនាសម្ព័ន្ធចំនួន ១៥ បានទទួលមូលនិធិគាំទ្រពីកាណាដា និងយូអិនឌីភី។

ការរីកចម្រើនខ្លះៗមកទល់ពេលនេះគឺ៖

- នៅខេត្តបាត់ដំបង ផ្លូវជនបទចំនួនបីខ្សែ ដែលមានប្រវែងសរុបប្រមាណ ៤.៥០០ម ក្នុងឃុំចំនួនបី ត្រូវបានកែលម្អ សម្រាប់អ្នកភូមិប្រើប្រាស់ជាច្រកដោះខ្លួនពីទឹកជំនន់។គម្រោងទាំងនេះចំណាយទឹកប្រាក់សរុបប្រមាណ ៥៨.៥៥០ដុល្លាអាមេរិក។



Photo: UNDP Cambodia

*អ្នកភូមិប្រមូលគ្នានៅក្បែរស្រះទឹកថ្មីមួយ នៅភូមិដាន ស្រុកគូលែន ខេត្តព្រះវិហារ ដែលទើបនឹងជីកហើយតាមរយៈការឧបត្ថម្ភមូលនិធិបន្សាំការប្រែប្រួលអាកាសធាតុតាមរយៈ UNDP ។*

- នៅខេត្តព្រះវិហារ៖
  - ផ្លូវថ្នល់មួយខ្សែប្រវែង ៩៤០ ម នៅឃុំទឹកក្រហម ត្រូវបានលើកខ្ពស់ជាងនីវ៉ូទឹកជំនន់ ដោយចំណាយអស់ប្រមាណ ២៣.៥៩០ ដុល្លាអាមេរិក។
  - ស្រះទឹកមួយ ( ៣០ x ៥៥ x ៣ម ) នៅភូមិដាន ឃុំថ្មី ត្រូវបានសាងសង់ដើម្បីត្រងទឹកភ្លៀងសម្រាប់ការប្រើប្រាស់តាមលំនៅស្ថាន។ គម្រោងនេះចំណាយអស់ប្រមាណ ១១.២៧៥ ដុល្លាអាមេរិក។
  - អាងទឹកមួយត្រូវបានស្តារឡើងវិញដើម្បីគ្រប់គ្រងការផ្គត់ផ្គង់ទឹកដល់ផ្ទៃដីទំហំ ៥៩០ ហិកតា ក្នុងឃុំព្រីងធំ។ គម្រោងនេះ ចំណាយអស់ ៤៥.៣៧៥ ដុល្លាអាមេរិក។

# ការស្តារឡើងវិញក្រោយទឹកជំនន់...

*តមកពីទំព័រទី ១*



PHOTO: UNDP Cambodia

*អ្នកភូមិកំពុងបរគោយន្តដឹកស្រូវនៅលើផ្លូវលំមួយក្នុងខេត្តសៀមរាប។ ផ្លូវនេះត្រូវបានស្តារឡើងវិញបន្ទាប់ពីត្រូវខូចខាតដោយទឹកជំនន់ឆ្នាំ 2013 តាមរយៈមូលនិធិពីអ្នកផ្តល់ជំនួយសម្រាប់ស្តារការខូចខាតដោយទឹកជំនន់។*

តាមសំណើរបស់រដ្ឋាភិបាលកម្ពុជា ការិយាល័យយូអិនឌីភីនៅកម្ពុជា បានធ្វើការវាយតម្លៃតម្រូវការនៅដំណាក់កាលដើមដំបូងក្រោយទឹកជំនន់ដែលផ្តល់តួលេខប៉ាន់ស្មានអំពីថ្លៃខូចខាតត្រូវជាប្រមាណ ៣៥៦លានដុល្លាអាមេរិក។ក្នុងតួលេខនេះ១៥៣លានដុល្លាអាមេរិកបណ្តាលពីការខូចខាតសម្បត្តិរូបវន្តនៅក្នុងតំបន់រងគ្រោះ និង ២០៣លានដុល្លាអាមេរិក ជាការបាត់បង់ផលិតកម្ម និងលំហូរសេដ្ឋកិច្ច។ របាយការណ៍នេះ ដែលបានចែករម្លែកទូទៅ ក្នុងចំណោមស្ថាប័នរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ បាននាំឲ្យមានការកៀរគរជំនួយឥតសំណង និងប្រាក់កម្ចីប្រមាណ ២០០លានដុល្លាអាមេរិក ពីម្ចាស់ជំនួយ សម្រាប់គម្រោងសាងសង់ឡើងវិញនានា ដែលគម្រោងខ្លះបានបញ្ចប់ និងគម្រោងខ្លះកំពុងអនុវត្តនៅឡើយ។

ឯកឧត្តម ញឹម វណ្ណដា អនុប្រធានទីមួយនៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយបានពោលថា “យើងសូមសំដែងការកោតសរសើរយ៉ាងជ្រាលជ្រៅដល់យូអិនឌីភី ចំពោះការគាំទ្រទាន់ពេលវេលា និងដ៏មានប្រសិទ្ធភាពនេះ ដល់ការវាយតម្លៃតម្រូវការស្តារឡើងវិញនៅដំណាក់កាលដំបូងក្រោយជំនន់នៅកម្ពុជា ឆ្នាំ ២០១៣”។

កម្ពុជា ត្រូវបានចាត់ទុកថាជាប្រទេសមួយក្នុងចំណោមប្រទេសនានាដែលងាយប្រឈមនឹងមុខសញ្ញាមហន្តរាយនៅអាស៊ីអាគ្នេយ៍។ គ្រោះមហន្តរាយធំៗដែលប្រទេសនេះបានប្រឈមគឺ ទឹកជំនន់ គ្រោះរាំងស្ងួត ព្យុះទីផុង និងខ្យល់ព្យុះ។ ដោយមានប្រជាជនប្រមាណ ៧០% រស់នៅតាមទីជនបទ និងពឹងផ្អែកលើកសិកម្មសម្រាប់តែមួយចំអែត គ្រោះមហន្តរាយធម្មជាតិអាចបង្កផលវិបាកប្រកបដោយការបំផ្លាញមកលើការចិញ្ចឹមជីវិតរបស់ប្រជាជនកម្ពុជាភាគច្រើន។

នៅខេត្តសៀមរាប ជំនន់ឆ្នាំ២០១៣ បានបង្កការខូចខាតផ្លូវជនបទជិត ៣០០គ.ម។ ក្នុងចំណោមការខូចខាតទាំងនេះ ១៤០គ.ម ឬ ត្រូវជា ៤៦% នៃកំណាត់ផ្លូវដែលខូចខាតទាំងស្រុង ឥឡូវនេះបានស្តារឡើងវិញតាមរយៈអន្តរាគមន៍នៅក្រោមជំនួយមូលនិធិពីធនាគារពិភពលោក រដ្ឋាភិបាលអូស្ត្រាលីតាមរយៈធនាគារអភិវឌ្ឍន៍អាស៊ី និងរដ្ឋាភិបាលកូរ៉េខាងត្បូង។

នៅភូមិគោកធ្នង់ ខេត្តសៀមរាប ការរស់នៅ គឺជាការតស៊ូជាប្រចាំ ដូចនៅក្នុងភូមិនានាដទៃទៀតក្នុងតំបន់ទំនាបបឹងទន្លេសាបផងដែរ។ នៅក្រោយជំនន់ឆ្នាំ ២០១៣ ដែលបានបំផ្លាញទាំងស្រុងផលដំណាំស្រូវរបស់គាត់ អ្នកស្រី ងុង ឌឿន អាយុ ៣៦ឆ្នាំ ត្រូវបានបង្ខំចិត្តធ្វើចំណាកស្រុកជាមួយប្តីគាត់ទៅធ្វើការតាមការដ្ឋានសំណង់ឆ្ងាយពីផ្ទះ ដោយបន្សល់ទុកកូនទាំងបួននៅក្រោមការថែទាំរបស់ឪពុកម្តាយគាត់។ នោះជាដំណោះស្រាយបណ្តោះអាសន្នរបស់ពួកគាត់ដើម្បីរកប្រាក់ចំណូលចាំបាច់សម្រាប់ទ្រទ្រង់គ្រួសាររបស់ខ្លួន។

ចាប់តាំងពីបានសាងសង់ផ្លូវនៅក្នុងភូមិនេះឡើងវិញ ឥឡូវនេះគាត់មានភាពងាយស្រួលជាងមុនក្នុងការធ្វើដំណើរទៅធ្វើការនៅតាមវាលស្រែរបស់គាត់ ចំណែកប្តីគាត់អាចទៅធ្វើការដោយសុវត្ថិភាពក្នុងភូមិនានាជិតខាង ដើម្បីរកប្រាក់ចំណូលសម្រាប់ទ្រទ្រង់គ្រួសារ។

អ្នកស្រី ងុង ឌឿន ពោលថា “ឥឡូវនេះ នៅពេលដែលផ្លូវនេះបានស្តារឡើងវិញ ខ្ញុំអាចធ្វើដំណើរដោយងាយស្រួលទៅកាន់ទីប្រជុំជន។ ទាំងគ្រួសាររបស់ខ្ញុំ និងអ្នកភូមិដទៃទៀតរីករាយណាស់”។

លោក ចាន់ ម៉ន បុរសចំណាស់អាយុ ៨០ ឆ្នាំ ក៏រីករាយផងដែរ ដោយបានពោលថា រូបគាត់ និងគ្រួសារឥឡូវនេះអាចធ្វើដំណើរទៅមន្ទីរពេទ្យជាទៀងទាត់ដើម្បីទទួលការពិនិត្យសុខភាពដោយសារតែគម្រោងសាងសង់ឡើងវិញក្រោយទឹកជំនន់។

# កម្មវិធីពហុព័ត៌មានពិភាក្សាបញ្ហាការងាររបស់យុវជនកម្ពុជា




PHOTO: UNDP Cambodia

*រូបពីឆ្វេងទៅស្តាំ លោកស្រី អាណា ម៉ាជ ហ៊ុលហ្គាដ ឯកអគ្គរដ្ឋទូតប្រទេសស៊ុយអែដ លោកស្រី មេហ្គាន់ ម៉ាក់បេន ប្រធាន BBC Media Action ប្រចាំកម្ពុជា និងលោកស្រី សេតស៊ូកូ យ៉ាម៉ាហ្សាគី ប្រធានយូអិនឌីភីប្រចាំកម្ពុជា សម្ពោធកម្មវិធី “ក្លាហាន៩” កាលពីថ្ងៃ ១១ មីនា ២០១៥។*

ស៊ុយអែដ និង យូអិនឌីភី បានប្រកាសជាផ្លូវការ កាលពីថ្ងៃពុធទី១១ ខែមីនា កម្មវិធីរួមគ្នាមួយសំដៅជួយយុវជនកម្ពុជាក្នុងបញ្ហារកការងារធ្វើ។ កម្មវិធីកិច្ចផ្តួចផ្តើមពហុព័ត៌មានសម្រាប់យុវជនកម្ពុជា “ក្លាហាន៩” បានចាប់ផ្តើមក្នុងពេលសមស្របមួយដែលកម្ពុជាកំពុងត្រៀមខ្លួនធ្វើសមាហរណកម្មសេដ្ឋកិច្ចអាស៊ាននៅចុងឆ្នាំនេះ។

លោកស្រី អាណា ម៉ាជ ហ៊ុលហ្គាដ ឯកអគ្គរដ្ឋទូតនៃប្រទេសស៊ុយអែដមានប្រសាសន៍នៅក្នុងពិធីចុះហត្ថលេខាដើម្បីប្រកាសចាប់ផ្តើមកម្មវិធី ”ក្លាហាន៩” ថា “ខ្ញុំមានសេចក្តីរីករាយជាពិសេស ជាមួយការផ្តោតលើយុវជន និងការងារ។ នេះជាប្រការសំខាន់សម្រាប់បុគ្គលនានា ក៏ដូចជា សម្រាប់សង្គមទាំងមូលផងដែរដើម្បីរីកចម្រើន និងបន្តលូតលាស់”។

ក្នុងពេលដែលសមាហរណកម្មថ្នាក់តំបន់មានន័យថាជាឱកាសថ្មីៗសម្រាប់កំណើន វាក៏នាំមកនូវបញ្ហាជាច្រើនផងដែរដែលប្រឈមចំពោះពលរដ្ឋវ័យក្មេង ក្នុងការប្រកួតប្រជែងជាមួយអ្នកដទៃ នៅពេលដែលមានលំហូរពាណិជ្ជកម្ម ការវិនិយោគ និងពលកម្មច្រើនជាងមុនឆ្លងកាត់ព្រំដែននៅក្នុងតំបន់នេះ។

ពលរដ្ឋវ័យក្មេងកម្ពុជាជាកម្លាំងពលកម្មយ៉ាងធំ ប៉ុន្តែពួកគេនៅប្រឈមឧបសគ្គជាច្រើន ដែលរារាំងពួកគេពីការរួមចំណែកប្រកបដោយអត្ថន័យនៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ច។ ការសិក្សាមួយដោយទីភ្នាក់ងារជាតិការងារ និងមុខរបរ នៅឆ្នាំ២០១៣ បានរកឃើញថា ពលរដ្ឋវ័យក្មេងច្រើនតែខ្វះជំនាញ និងទំនុកចិត្ត នៅពេលត្រៀមខ្លួនដើម្បីស្វែងរកការងារ។ ការសិក្សាមួយផ្សេងទៀតដោយអង្គការពលកម្មអន្តរជាតិក៏បានរកឃើញផងដែរនូវសមាមាត្រយ៉ាងធំនៃភាពមិនស្របគ្នារវាងការអប់រំ និងជំនាញដែលត្រូវការជាចាំបាច់នៅក្នុងទីផ្សារការងារដោយសារខ្វះលទ្ធភាពទទួលបានព័ត៌មានដើម្បីជួយពលរដ្ឋវ័យក្មេងក្នុងការធ្វើសេចក្តីសម្រេចអំពីអ្វីដែលពួកគេគួរសិក្សា។ ប្រពៃណីក្នុងគ្រួសារក៏ធ្វើឲ្យមានការលំបាកសម្រាប់ស្ត្រីវ័យក្មេងដើម្បីជ្រើសយកអាជីពរបស់ពួកគេផងដែរ ដែលធ្វើឲ្យពួកគេស្ថិតក្នុងស្ថានភាពចាញ់ប្រៀបធៀបនឹងបុរសវ័យក្មេង។

លោកស្រី សេតស៊ូកូ យ៉ាម៉ាហ្សាគី នាយកយូអិនឌីភីប្រចាំនៅកម្ពុជា មានប្រសាសន៍នៅក្នុងពិធីចុះហត្ថលេខានេះថា ការបានទទួលភាគលាភប្រជាសាស្ត្រនៅពុំទាន់គ្រប់គ្រាន់ឡើយសម្រាប់កម្ពុជា។

លោកស្រីយ៉ាម៉ាហ្សាគី មានប្រសាសន៍ថា “ប្រការសំខាន់សម្រាប់កម្ពុជា គឺត្រូវមានកម្លាំងពលកម្មប្រកបដោយគុណភាពដែលនឹងបង្កើតផលចំណូលសម្រាប់ប្រទេស ដែលរដ្ឋាភិបាលអាចបែងចែកទៅក្រុមប្រជាពលរដ្ឋផ្សេងៗទៀតតាមរយៈប្រព័ន្ធសេវាកម្មសាធារណៈ”។

លោកស្រីមានប្រសាសន៍ថា “ក្លាហាន៩” ដែលអនុវត្តដោយ BBC Media Action គឺជាគោលដៅថ្មីមួយនៅក្នុងកិច្ចប្រឹងប្រែងរួមគ្នា “ដើម្បីជួយផ្តល់ឲ្យពលរដ្ឋវ័យក្មេងនៅកម្ពុជា ជាពិសេស ស្ត្រីវ័យក្មេង នូវចំណេះដឹង និងសមត្ថភាពចាំបាច់ ដើម្បីឈានឆ្ពោះទៅរកឱកាសការងារ និងរបរចិញ្ចឹមជីវិតប្រសើរជាងមុន”។

“ក្លាហាន៩” ពង្រឹងជាបន្ថែមនូវជោគជ័យនៃកម្មវិធីអប់រំយុវជនកន្លងមក ពោលគឺកម្មវិធី “ឡូយ៩” ដែលបានទទួលការគាំទ្រហិរញ្ញវត្ថុពីប្រទេសស៊ុយអែដផងដែរ។ កម្មវិធីថ្មីនេះនឹងអនុវត្តកិច្ចការចំបងៗចំនួនពីរ ជាអាទិ៍៖

- ការអប់រំអំពីការងារដែលផ្តោតលើយុវជន ដោយបង្កើតវេទិកាព័ត៌មាន កម្មវិធី និងសកម្មភាពផ្សព្វផ្សាយនានានៅតាមសហគមន៍ និង
- ការអភិវឌ្ឍសមត្ថភាពសម្រាប់យុវជនកម្ពុជា តាមរយៈការធ្វើការជាមួយទីភ្នាក់ងារជាតិការងារ និងមុខរបរ និងសេវាផ្សព្វផ្សាយរបស់កម្ពុជាតាមមធ្យោបាយនៃការផ្សាយព័ត៌មានខុសៗគ្នា។

ប្រធានបទនានាដែលទាក់ទងនឹងការងារនឹងត្រូវរៀបចំឡើងតាមទម្រង់ខុសៗគ្នា ដូចជា ល្ខោនទូរទស្សន៍ និង ការទទួលទូរស័ព្ទក្នុងកម្មវិធីតាមវិទ្យុ មាតិកាតាមប្រព័ន្ធអេឡិចត្រូនិក និងពិធីនានា។

កម្មវិធីនេះមានថវិកាចំនួន ១,៥ លានដុល្លាអាមេរិកពីប្រទេសស៊ុយអែដ និង ៥១២.០០០ ដុល្លាអាមេរិក ពីយូអិនឌីភី និងត្រូវអនុវត្តរហូតដល់ខែមីនា ឆ្នាំ២០១៥។




PHOTO: UNDP Cambodia

*រូបពីឆ្វេង លោកស្រី សេតស៊ូកូ យ៉ាម៉ាហ្សាគី ប្រធានយូអិនឌីភីប្រចាំកម្ពុជា និង លោកស្រី អាណា ម៉ាជ ហ៊ុលហ្គាដ ឯកអគ្គរដ្ឋទូតប្រទេសស៊ុយអែដ ផ្តល់បទ សម្ភាសន៍ក្នុងពេលសម្ពោធកម្មវិធី “ក្លាហាន៩” កាលពីថ្ងៃ ១១ មីនា ២០១៥។*

# កម្មវិធីប្រែប្រួលអាកាសធាតុនៅកម្ពុជា បានទទួលការគាំទ្របន្តពីសហភាពអឺរ៉ុប ស៊ុយអែដ និងយូអិនឌីភី




PHOTO: UNDP Cambodia

*ឯកឧត្តម សាយ សំអាល់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងលោកស្រីសេតស៊ូកូ យ៉ាម៉ាហ្សាគី នាយកយូអិនឌីភី នៅកម្ពុជា ក្នុងពិធីចុះហត្ថលេខាបន្តការគាំទ្រហិរញ្ញវត្ថុដល់តំណាក់កាលទីពីររបស់កម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា កាលពីថ្ងៃ ១២ មីនា ២០១៥។*

កិច្ចប្រឹងប្រែងរបស់កម្ពុជាដើម្បីដោះស្រាយការគំរាមកំហែងនៃការប្រែប្រួលអាកាសធាតុត្រូវបានពង្រឹងតាមរយៈការបន្តគាំទ្រហិរញ្ញវត្ថុពីសហភាពអឺរ៉ុប ស៊ុយអែដ និងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ កាលពីថ្ងៃទី១២ មីនា កន្លងទៅនេះ។

សហភាពអឺរ៉ុបសន្យាផ្តល់ជាង ៥០% នៃវិភាគទានរួមសម្រាប់តំណាក់កាលទីពីររបស់កម្មវិធី សម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា (CCCA) រហូតដល់ឆ្នាំ ២០១៩។

ឯកឧត្តម សាយ សំអាល់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន មានប្រសាសន៍នៅក្នុងពិធីចុះហត្ថលេខាកាលពីថ្ងៃ ទី១២ ខែមីនា ថា "តំណាក់កាលទីពីរនេះនឹងផ្តោតទៅលើការអនុវត្តយុទ្ធសាស្ត្រនិងផែនការនានាដែលបានដាក់ចេញក្នុងតំណាក់កាលទីមួយកន្លងមក"។

ឯកឧត្តមបានបន្តថា ជាមួយគ្នានេះ "កម្មវិធីនេះនឹងផ្តោតការយកចិត្តទុកដាក់ខ្លាំងក្លាលើការអភិវឌ្ឍធនធានបច្ចេកវិទ្យា និងធនធានមនុស្ស ដែលចាំបាច់សម្រាប់ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ តាមរយៈជំនួយឥតសំណងសម្រាប់ការស្រាវជ្រាវ និងភាពជាដៃគូជាមួយវិស័យអប់រំ"។

សហភាពអឺរ៉ុបគ្រោងផ្តល់ទឹកប្រាក់ចំនួន ៦ លានអឺរ៉ូ ដែលជាភាគចំណែកច្រើនជាងគេ បន្ទាប់មកគឺទឹកប្រាក់ ៣,៨ លានដុល្លាអាមេរិក ពីប្រទេសស៊ុយអែដ និង ១,១៥ លានដុល្លាពីយូអិនឌីភី។

លោក ហ្សង់ ហ្វ្រង់ស្វ័រ កូតាំង មានប្រសាសន៍ថា បន្ថែមលើការជួយកម្ពុជាក្នុងការដោះស្រាយបញ្ហាការប្រែប្រួលអាកាសធាតុ សហភាពអឺរ៉ុប "គ្រោងនឹងផ្តល់ទឹកប្រាក់ ១៤៩ លានអឺរ៉ូរហូតដល់ឆ្នាំ ២០២០ សម្រាប់គម្រោង វិស័យគ្រប់គ្រងធនធានធម្មជាតិ" នៅកម្ពុជា។

លោកស្រី អាណា ម៉ាជ ហ៊ុលហ្គាដ ឯកអគ្គរដ្ឋទូតស៊ុយអែដប្រចាំនៅកម្ពុជា ថ្លែងថាគាត់មានសង្ឃឹមថាការឧបត្ថម្ភថវិកាថ្មីនេះនឹងនាំ "ឲ្យមានកិច្ចខិតខំកាន់តែខ្លាំងថែមទៀតនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ក្នុងធ្វើឲ្យការឆ្លើយតបឲ្យកាន់តែមានប្រសិទ្ធភាព និងបង្កើនភាពធន់របស់ប្រទេសទៅនឹងការប្រែប្រួលអាកាសធាតុ"។

ការសិក្សាថ្មីៗនេះបានរកឃើញជាបន្តបន្ទាប់ថា កម្ពុជាស្ថិតក្នុងចំណោមប្រទេសនានាដែលងាយរងគ្រោះបំផុតចំពោះការប្រែប្រួលអាកាសធាតុ ដោយសារតែការពឹងផ្អែកជាខ្លាំងលើកសិកម្ម នៃប្រជាពលរដ្ឋមួយភាគធំដែលរស់នៅក្នុងតំបន់ទំនាបនិងសមត្ថភាពទាបក្នុងការទប់ទល់ចំពោះព្រឹត្តិការណ៍ធាតុអាកាសដែលមិនអាចព្យាករណ៍បាន និងមិនប្រក្រតី ដូចជា គ្រោះរាំងស្ងួត និងទឹកជំនន់។

កម្មវិធី CCCA ត្រូវបានបង្កើតឡើងនៅ ខែកុម្ភៈ ឆ្នាំ២០១០ ជាកម្មវិធីពហុម្ចាស់ជំនួយ ដើម្បីផ្តល់ធនធានសម្រាប់កិច្ចផ្តួចផ្តើមប្រែប្រួលអាកាសធាតុ។ ម្ចាស់ជំនួយនៅក្នុងដំណាក់កាលប្រាំឆ្នាំលើកទីមួយមាន សហភាពអឺរ៉ុប ស៊ុយអែដ ដាណឺម៉ាក់ និងយូអិនឌីភី។ ចាប់តាំងពីពេលចាប់ផ្តើម កម្មវិធីនេះបានផ្តល់ការគាំទ្រដល់រដ្ឋាភិបាលក្នុងការរៀបចំក្របខ័ណ្ឌគោលនយោបាយប្រែប្រួលអាកាសធាតុ និងការអនុវត្តគម្រោងនានានៅថ្នាក់មូលដ្ឋានចំនួន ២០ ក្នុងគោលដៅសាកល្បងវិធានការនានាដើម្បីកែលម្អភាពធន់នៃសហគមន៍ជនបទដែលងាយរងគ្រោះបំផុតដោយសារការប្រែប្រួលអាកាសធាតុ។ នៅចុងឆ្នាំ ២០១៣ រដ្ឋាភិបាលបានប្រកាសផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុកម្ពុជា ដើម្បីផ្តល់ជាគោលការណ៍ណែនាំសម្រាប់លើកកំពស់ការអភិវឌ្ឍដែលបំភាយកាបូនទាប និងធន់នឹងអាកាសធាតុសម្រាប់រយៈពេល ១០ឆ្នាំខាងមុខ។

លោកស្រី សេតស៊ូកូ យ៉ាម៉ាហ្សាគី នាយកយូអិនឌីភីនៅកម្ពុជា មានប្រសាសន៍នៅក្នុងពិធីនេះថា

"ដោយធ្វើការជាមួយគ្នា យើងពិតជាអាចសម្រេចបានចក្ខុវិស័យ និងកិច្ចប្រឹងប្រែងរួមគ្នារបស់យើងជាច្រើនបន្ថែមទៀត ដើម្បីលើកកំពស់វិធានការរបស់កម្ពុជាក្នុងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ដើម្បីទ្រទ្រង់និរន្តរភាពនៃកំណើន និងកសាងភាពធន់នៃប្រជាពលរដ្ឋដែលងាយរងគ្រោះ ដើម្បីឲ្យចាកផុតពីភាពក្រីក្រ"។




PHOTO: UNDP Cambodia

*លោកហ្សង់ ហ្វ្រង់ស្វ័រ កូតាំងឯកអគ្គរដ្ឋទូតសហភាពអឺរ៉ុប និងលោកស្រីសេតស៊ូកូ យ៉ាម៉ាហ្សាគី នាយកយូអិនឌីភីនៅកម្ពុជា ក្នុងពិធីចុះហត្ថលេខាបន្តការគាំទ្រហិរញ្ញវត្ថុដល់តំណាក់កាលទីពីររបស់កម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា កាលពីថ្ងៃ ១២ មីនា ២០១៥។*

# ប្រតិភូឡាវធ្វើទស្សនកិច្ចសិក្សាអំពីកសិកម្ម បន្សាំការប្រែប្រួលអាកាសធាតុ

ទោះជាដល់ពេលសម្រាកពិសាអាហារថ្ងៃត្រង់ហើយក្តី ក្រុមភ្ញៀវឡាវនៅតែបន្តសួរសំណួរ និង ប្រឹងកត់ត្រាអំពីរូបមន្តសម្រាប់ផ្សំថ្នាំកំចាត់សត្វល្អិតចង្រៃ និងជីសរីរាង្គ។ អ្នកទទួលភ្ញៀវរបស់ពួកគេ អ្នកស្រី គុយ សាមឿន ដែលជាកសិករគំរូកម្ពុជាម្នាក់ផ្នែកដំណាំចម្រុះ ពុំបានបង្ហាញពីការនឿយហត់ឡើយ ដោយប្រឹងប្រាប់ ពួកភ្ញៀវឡាវនូវគ្រប់គន្លឹះនៃការដាំដំណាំសរីរាង្គ ដែលក្រុមភ្ញៀវចង់ដឹងនោះ ក៏ដោយ។



Photo: UNDP Cambodia/Naratevy Kek

*សមាជិកគណៈប្រតិភូឡាវកំពុងស្តាប់អ្នកស្រី គុយ សាមឿន រូបទីបីពីឆ្វេងពាក់អាវពណ៌ផ្កាឈូក ពន្យល់អំពីរបៀបធ្វើជីសរីរាង្គក្នុងអំឡុងពេលទស្សនកិច្ចនៅឃុំទឹកក្រហម ខេត្តព្រះវិហារ កាលពីខែកុម្ភៈ កន្លងទៅនេះ។*

អ្នកស្រី ផុនសាវ៉ាន់ ស៊ីសាវ មកពីខេត្តសាវ៉ាន់ណាខេត ក្នុងប្រទេសឡាវ ពោលថា "នេះជាអ្វីដែលយើងអាចពាំនាំទៅចែករំលែកជាមួយកសិករនៅក្នុងប្រទេសរបស់យើងបាន"។

គាត់ជាអ្នកសម្របសម្រួលថ្នាក់ខេត្ត និងជាមនុស្សម្នាក់ក្នុងចំណោមតំណាងចំនួន ២៥ នាក់មកពីប្រទេសឡាវ ដែលបានចូលរួមនៅក្នុងទស្សនកិច្ចសិក្សាមួយរយៈពេលបួនថ្ងៃកាលពីពាក់កណ្តាលខែកុម្ភៈ តាមរយៈគម្រោងដែលគាំទ្រដោយ យូអិនឌីភី។ ពួកគេបានមកធ្វើទស្សនកិច្ចនៅទីតាំងនានានៃគម្រោង "លើកកំពស់ការគ្រប់គ្រងទឹក និងទម្លាប់ក្នុងកសិកម្មដែលធន់នឹងអាកាសធាតុ" ក្នុងខេត្តក្រចេះ និងព្រះវិហារ និងគម្រោងផ្សេងទៀតដែលគាំទ្រដោយកម្មវិធីជំនួយខ្នាតតូច នៅក្នុងខេត្តសៀមរាប។

ទស្សនកិច្ចមកពីគម្រោង "កែលម្អភាពធន់នៃវិស័យកសិកម្មទល់នឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុក្នុងប្រទេសឡាវ" (IRAS) មានគោលដៅបង្កើនបទពិសោធន៍ អំពីទម្លាប់នៃការបន្សាំនៅក្នុងវិស័យកសិកម្មតបនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។ ពួកគេបានជួបកសិករខ្មែរ ដូចជា អ្នកស្រី គុយ សំអឿន ដែលបាន និងកំពុងទទួលផលពីអន្តរាគមន៍របស់ការិយាល័យយូអិនឌីភីនៅកម្ពុជា ដូចជាប្រព័ន្ធបូមទឹកដោយថាមពលព្រះអាទិត្យ និងវិធីធ្វើកសិកម្មចម្រុះ ដើម្បីបង្កើនភាពធន់ចំពោះការប្រែប្រួលអាកាសធាតុ និងរបរចិញ្ចឹមជីវិតរបស់ពួកគេ។

អ្នកស្រី វិល័យផន វ៉ាភិម អគ្គនាយករងនៃការិយាល័យលេខាធិការអចិន្ត្រៃយ៍ ក្រសួងកសិកម្មឡាវ បានគូសបញ្ជាក់អំពីមេរៀនសំខាន់ៗចំនួនបីសម្រាប់ការពាំនាំយកទៅប្រទេសខ្លួនវិញពីទស្សនកិច្ចនៅកម្ពុជា៖ ការប្រើប្រាស់ប្រព័ន្ធបូមទឹកដោយថាមពលព្រះអាទិត្យដែលគម្រោងនៅក្នុងប្រទេសរបស់គាត់នៅពុំទាន់បានអនុវត្ត និងការចូលរួមដោយស្ម័គ្រចិត្តពីសហគមន៍នៅក្នុងគម្រោងទាំងនេះ។ ក្នុងប្រទេសរបស់គាត់ សមាជិកសហគមន៍ត្រូវបានបង់ថ្លៃ ដើម្បីឲ្យពួកគេអាចអនុវត្តតួនាទីរបស់ខ្លួននៅក្នុងក្រុមនេះ។ ទីបីគឺ ចំណេះដឹងអំពីបច្ចេកទេសបន្សុទ្ធពូជរបស់កសិករកម្ពុជាដើម្បីអាចឲ្យពួកគេជ្រើសយកពូជស្រូវដែលធន់ដោយខ្លួនឯង។ នៅប្រទេសឡាវ ពូជស្រូវត្រូវបានបន្សុទ្ធនៅស្ថានីយ៍មុននឹងបញ្ជូនទៅឲ្យកសិករ។

អ្នកស្រី វីល័យផន បានពោលថា "ខ្ញុំរីករាយណាស់ដែលបានទទួលចំណេះដឹង និងទម្លាប់ល្អខ្លះៗពីកសិករកម្ពុជា និងពីក្រុមអនុវត្តគម្រោងនេះ"។

ការប្រឈមចំពោះកសិករនៅក្នុងប្រទេសឡាវ និងកម្ពុជាមានលក្ខណៈប្រហែលគ្នា។ ទឹកជំនន់ និងគ្រោះរាំងស្ងួតកើតមានជាញឹកញាប់។ នៅក្នុងកិច្ចប្រឹងប្រែងដើម្បីដោះស្រាយការប្រឈមទាំងនេះ រដ្ឋាភិបាលឡាវបានលើកទឹកចិត្តដល់កសិករដែលមានចំនួនប្រជាជនរហូតដល់ ៨០% នៃចំនួនប្រជាជនសរុប ធ្វើការកែប្រែមុខដំណាំដែលផ្អែកលើការប្រែប្រួលអាកាសធាតុ ។ ឧទាហរណ៍ បើលក្ខខណ្ឌមិនអាចឲ្យពួកគេដាំស្រូវទេនោះពួកគេគួរដាំបន្លែជាជំនួស។ វិធីសាស្ត្រដូចគ្នានេះកំពុងត្រូវបានដាក់ឲ្យប្រើប្រាស់ដើម្បីជួយកសិករកម្ពុជា តាមរយៈគម្រោងខុសៗគ្នានៃការិយាល័យ យូអិនឌីភីនៅកម្ពុជា ដូចជា ការលើកកំពស់ការគ្រប់គ្រងទឹក និងទម្លាប់ធ្វើកសិកម្មដែលធន់នឹងអាកាសធាតុ ដែលបានទទួលមូលនិធិពីរដ្ឋាភិបាលប្រទេសកាណាដា។



Photo: UNDP Cambodia/Naratevy Kek

*សមាជិកគណៈប្រតិភូឡាវទៅទស្សនាសាលាបឋមសិក្សាគោកស្រឡៅ ខេត្តព្រះវិហារ ក្នុងអំឡុងទស្សនកិច្ចផ្លាស់ប្តូរបទពិសោធន៍ អំពីការបន្សាំការប្រែប្រួលអាកាសធាតុ កាលពីខែកុម្ភៈ កន្លងទៅនេះ។*

## ផ្ទៃដីសម្អាតមីនរួចបន្ថែមទៀត ត្រូវបានប្រគល់ជូនកសិករ

ប្រតិបត្តិការបោសសំអាតគ្រាប់មីន ដែលគាំទ្រដោយ យូអិនឌីភី ទើបតែបានប្រគល់ផ្ទៃដីទំហំ ២៦,៥គ.ម$^{២}$ បន្ថែមទៀត ដល់កសិករកម្ពុជាប្រើប្រាស់សម្រាប់បង្កបង្កើនផល នៅក្រោយពេលត្រូវបានបោសសំអាតគ្រាប់មីន និងសំណល់គ្រឿងផ្ទុះ ពីសម័យសង្គ្រាម (ERW) នៅឆ្នាំ ២០១៤ រួចមក។ គេរំពឹងថា អ្នកភូមិប្រមាណ ៣៥.០០០ នាក់ ក្នុងនោះ ៥៤% ជាស្ត្រី ក្នុងខេត្តភាគពាយព្យ ពោលគឺ បាត់ដំបង បន្ទាយមានជ័យ និងប៉ៃលិន នឹងទទួលផលពីដីនេះ។

តំបន់នេះមានគ្រាប់មីនបង្កប់ក្នុងដី និង ERWs យ៉ាងច្រើន ដែលបន្សល់ទុកពីសម័យជម្លោះផ្ទៃក្នុងកម្ពុជា ដែលបានបញ្ចប់នៅចុងទសវត្សរ៍ឆ្នាំ១៩៩០។ ចាប់ពីឆ្នាំ២០០៦មក ការងារបោសសំអាតគ្រាប់មីនដែលគាំទ្រដោយយូអិនឌីភី បានបោសគ្រាប់មីនពីផ្ទៃដីទំហំជិត១១០គ.ម$^{២}$ដោយបានបង្វែរអតីតសមរភូមិឲ្យទៅជាតំបន់ដាំដំឡូងមីដ៏ធំមួយនៃក្នុងប្រទេស។

លោក សៀម សារ៉េត កសិករអាយុ ៤៨ ឆ្នាំ នៅប៉ៃលិន បានពោលថា "យើងធ្លាប់ដាំពោត និងលក់ពោតនៅក្នុងមូលដ្ឋាននេះ ប៉ុន្តែខ្ញុំរកប្រាក់ចំណូលមិនបានច្រើនដូចការដាំដំឡូងឡើយ"។

លោក ម៉ុត សាមុត កសិករម្នាក់ទៀតនៅក្នុងខេត្តដដែលនេះបានបន្ថែមថា "ប្រាក់ចំណូលប្រចាំឆ្នាំរបស់ខ្ញុំ នៅមុនដាំដំឡូងមីមានប្រមាណ ១.២៣០ ដុល្លាអាមេរិក ហើយឥឡូវនេះប្រាក់ចំណូលប្រចាំឆ្នាំបច្ចុប្បន្នរបស់ខ្ញុំគឺ ៣.០៧០ដុល្លាអាមេរិក"។

បុរសទាំងពីរនាក់បានពោលថា ពួកគេអាចរកប្រាក់បានច្រើនជាងមុនដោយពួកគាត់អាចពង្រីកដីចំការក្រោយពេលដែលគ្រាប់មីនបង្កប់ក្នុងដី និង ERWs ត្រូវបានបោសសម្អាតរួច។

អ្នកស្រី ឃិត សារិន ប្រធានភូមិតាំងសួរ ខេត្តប៉ៃលិន បានពោលថា ការបោសសំអាតគ្រប់មីនបានរួមចំណែកដោយផ្ទាល់ចំពោះការអភិវឌ្ឍនៅមូលដ្ឋានជាពិសេសតាមរយៈការពង្រីកទំហំដីដែលបានសង្គ្រោះពីគ្រាប់មីនសម្រាប់កសិករប្រើប្រាស់។ អ្នកស្រីបានពោលថា "ការបោសសំអាតគ្រាប់មីន ក៏មានឥទ្ធិពលមកលើកំណែលម្អហេដ្ឋារចនាសម្ព័ន្ធផងដែរ ដូចជាសាលារៀន និងការសាងសង់ផ្លូវថ្នល់ដែលមានសុវត្ថិភាព។ ការភ័យខ្លាចក្នុងការប្រើប្រាស់ដីបានថយចុះ ហើយសហគមន៍មានអារម្មណ៍ទុកចិត្តកាន់តែច្រើនឡើងក្នុងការប្រើប្រាស់ និងការវិនិយោគលើដីធ្លី។ ចាប់ពីឆ្នាំ ២០១២មក ការដាំដំឡូងមី គឺជាឱកាសចំបងមួយសម្រាប់ការរកប្រាក់ចំណូល"។

ប្រធានភូមិ និងកសិករទាំងពីររូប ពោលថា នេះមានន័យថា តម្រូវការដីសម្រាប់ដាំដំណាំនៅតែមានកម្រិតខ្ពស់នៅឡើយ ក៏ដូចជាតម្រូវការឲ្យមានប្រតិបត្តិការកំចាត់សំណល់គ្រឿងផ្ទុះ ដើម្បីអ្នកភូមិអាចបង្កើនការប្រើប្រាស់ដីសម្រាប់កសាងជីវភាពឲ្យបានប្រសើរជាងមុនផងដែរ។

# វិនិយោគលើមូលធនមនុស្សដើម្បីចីរភាពកំណើនពេលអនាគត



PHOTO: UNDP Cambodia

*នាង វិន រតនា រូបកណ្ដាល កំពុងត្រួតពិនិត្យការជួសជុលរថយន្តនៅរោងជាងមួយក្នុងខេត្តសៀមរាប។ បន្ទាប់ពីបញ្ចប់ថ្នាក់វិទ្យាល័យ នាងមិនបានចូលរៀនសាកលវិទ្យាល័យភ្លាមទេដោយជីវភាពគ្រួសារយ៉ាប់យ៉ឺន ប៉ុន្តែនាងបានចូលរៀនសាលាជំនាញបច្ចេកវិទ្យាមួយដែលនាងបានប្រើប្រាស់បង្កើនជោគជ័យក្នុងអាជីពមកទល់សព្វថ្ងៃនេះ។ ក្នុងពេលដែលកម្ពុជាកំពុងត្រៀមខ្លួនចូលក្នុងសមាហរណកម្មសេដ្ឋកិច្ច អាស៊ាននាចុងឆ្នាំ 2015 មានភាពចាំបាច់កាន់តែខ្លាំងឡើងឲ្យមានការបង្កើនជំនាញកម្លាំងពលកម្ម និងវិនិយោគថែមទៀតលើមូលធនមនុស្សសម្រាប់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាពទៅអនាគត។*

បន្ទាប់ពីប្រឡងជាប់កម្រិតមធ្យមសិក្សាកាលពីដប់ឆ្នាំមុន ឪពុកម្ដាយរបស់នាង វិន រតនា ពុំមានប្រាក់គ្រប់គ្រាន់ ដើម្បីបញ្ជូនគាត់ចូលរៀននៅសកលវិទ្យាល័យភ្លាមៗនោះទេ។ ប៉ុន្តែនោះក៏មិនមែនជាចុងបញ្ចប់នៃផ្លូវអនាគតសម្រាប់នាងដែរដោយនាងបានចុះឈ្មោះចូលសាលាបណ្ដុះបណ្ដាលបច្ចេកទេស ដើម្បីរៀនជំនាញជួសជុលរថយន្ត វិញ។

វិន រតនា ដែលមានវ័យ ៣១ឆ្នាំ បានរំលឹកឡើងវិញថា "ពេលខ្ញុំមកលេងផ្ទះពេលសម្រាកការសិក្សា មិត្តភក្តិរបស់ខ្ញុំតែងសួរថា តើឯងរៀនអី? ខ្ញុំបានប្រាប់ពួកគេថាខ្ញុំរៀនជួសជុលឡាន និងប្រព័ន្ធអេឡិចត្រូនិក។ ពួកគេសើច ហើយនិយាយថា យើងជាស្រីមិនគួរទៅរៀនអាហ្នឹងទេ ព្រោះនៅពេលរៀនចប់ឯងនឹងមិនអាចជួសជុលឡានបានដូចប្រុសៗទេ"។

សព្វថ្ងៃនេះ នាងជាអ្នកគ្រប់គ្រងយានដ្ឋានមួយ ដែលលក់រថយន្តជប៉ុននៅខេត្តសៀមរាប។ តាមរយៈទទួលបានជំនាញបច្ចេកទេសមុនសញ្ញាបត្រឧត្តមសិក្សាដើម្បីឈានមកដល់ការងារបច្ចុប្បន្ននេះ នាង វិន រតនា បានផ្ដល់ជាគំរូមួយអំពី ចំណេះវិជ្ជាជំនាញបច្ចេកទេសដែលជាស្នូលនៃការពិភាក្សាអំពីរបៀបអភិវឌ្ឍន៍មូលធនមនុស្សនៅកម្ពុជា។

ប្រទេសនេះត្រៀមខ្លួនដើម្បីសមាហរណកម្មសេដ្ឋកិច្ចជាមួយអាស៊ាន នៅចុងឆ្នាំ២០១៥។ ប៉ុន្តែ គេនៅមានកង្វល់ច្រើននៅឡើយត្រង់ថា ការវិនិយោគតិចតួចលើមូលធនមនុស្ស ដែលនឹងបន្តកំហិតឱកាសសម្រាប់ពលរដ្ឋវ័យក្មេងរកការងារធ្វើ។ ប្រជាជនកម្ពុជាជិតពីរភាគបីមានអាយុក្រោម ៣០ឆ្នាំ ប៉ុន្តែជាមួយការអប់រំតិចតួច ភាគច្រើននៃកម្លាំងពលកម្មប្រកបដោយសក្ដានុពលទាំងនេះ បានត្រឹមតែមានការងារដែលទទួលបានកម្រៃទាបប៉ុណ្ណោះ។

ដូចក្នុងប្រទេសកំពុងអភិវឌ្ឍន៍ផ្សេងទៀតផងដែរ កម្ពុជាកំពុងឈានទៅរកសេដ្ឋកិច្ចពិភពលោកដែលផ្អែកលើចំណេះដឹង។ នោះមានន័យថា ប្រទេសកម្ពុជាត្រូវពង្រឹងភាពច្នៃប្រឌិត ជំនាញ និងនវានុវត្តន៍នៅក្នុងកម្លាំងពលកម្មរបស់ខ្លួន។ ប៉ុន្តែ ប្រព័ន្ធអប់រំសាធារណៈរបស់ប្រទេសនេះ បានទទួលថវិកាគាំទ្រមិនគ្រប់គ្រាន់ឡើយ ហើយសូម្បីតែនិស្សិតដែលបានទទួលការសិក្សាសមរម្យ ហើយក៏ដោយនៅតែប្រឈមបញ្ហាផងដែរ ដោយសារភាពប្រកួតប្រជែងក្នុងការងារកាន់តែតានតឹងឡើងៗ។

ឯកឧត្តម ហង់ ជួនណារ៉ុន រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា បានពោលនៅក្នុងការសម្ភាសមួយថា "នៅក្នុងរយៈពេលពីរទសវត្សរ៍កន្លងទៅ យើងផលិតបាននិស្សិតជាច្រើនខាងផ្នែកគណនេយ្យ និងធុរកិច្ច។ ប៉ុន្តែ យើងមានតែ ២,៥% នៃចំនួននិស្សិតទៅដែលរៀនខាងកសិកម្ម ហើយកម្ពុជាគឺជាប្រទេសកសិកម្ម។ យើងមាននិស្សិត ត្រឹមតែ ៣% ទេដែលរៀនវិស្វកម្ម ហើយកម្ពុជាត្រូវការវិស្វករ និងអ្នកបច្ចេកទេសថែមទៀត"។

ឯកឧត្តម បានបន្ថែមដោយពន្យល់អំពីយុទ្ធសាស្ត្ររបស់ក្រសួងនេះថា "ដើម្បីឲ្យកម្ពុជាឈានទៅមុខ យើងត្រូវបង្កើតវិស្វករ គ្រូពេទ្យបន្ថែមទៀត និងមនុស្សជាច្រើននៅក្នុងវិស័យដទៃទៀត មិនមែនត្រឹមតែក្នុងធុរកិច្ច និងគណនេយ្យប៉ុណ្ណោះទេ"។

រដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ឯកឧត្តម អ៊ិត សំហេង បានឯកភាព។ ឯកឧត្តមពោលថា រដ្ឋាភិបាលកំពុងបង្កើនការយកចិត្តទុកដាក់លើការផ្ដល់ឲ្យយុវជនកម្ពុជានូវជំនាញបច្ចេកទេស ដែលពួកគេត្រូវការដើម្បីប្រកួតប្រជែងនៅក្នុងក្របខ័ណ្ឌអាស៊ាន។ ឯកឧត្តមបានបន្ថែមថា វិស័យឯកជនក៏មានតួនាទីសំខាន់ផងដែរក្នុងកិច្ចការនេះ។

ឯកឧត្តមពោលថា "រាជរដ្ឋាភិបាលកម្ពុជា បានកំណត់រួចមកហើយថា វិស័យឯកជន គឺជាក្បាលរថភ្លើងដែលជម្រុញកំណើនរបស់យើង។ ភាពជាដៃគូនេះមានសារៈសំខាន់ពីរបែប នៅក្នុងការពង្រឹងសាលាបណ្ដុះបណ្ដាលវិជ្ជាជីវៈឯកជន និងក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការរវាងឧស្សាហកម្មឯកជន និងគ្រឹះស្ថានបណ្ដុះបណ្ដាលវិជ្ជាជីវៈរបស់រដ្ឋាភិបាល"។

ការអភិវឌ្ឍមូលធនមនុស្ស គឺជាវិស័យគន្លឹះមួយដែលយូអិនឌីភី កំពុងផ្ដល់ការគាំទ្រខាងគោលនយោបាយដល់យុទ្ធសាស្ត្រនានារបស់រដ្ឋាភិបាល ដែលនឹងជួយបង្កើតជំនាញ និងឱកាសការងារសម្រាប់ជនកម្ពុជាជាពិសេស យុវជន។

លោកស្រី សេតស៊ូកូ យ៉ាម៉ាហ្សាគី នាយកយូអិនឌីភីប្រចាំនៅកម្ពុជាបានពោលថា "មូលធនមនុស្សមានសារៈសំខាន់ណាស់។ ប៉ុន្តែ ទាល់តែគុណភាពនៃធនធានមនុស្ស និងកម្លាំងពលកម្ម មានលក្ខណៈល្អប្រសើរដើម្បីបន្ថែមគុណតម្លៃ ទើបពួកគេនឹងអាចរួមចំណែកទៅក្នុងសេដ្ឋកិច្ចជាតិ"។

វគ្គបណ្ដុះបណ្ដាលបច្ចេកទេសរយៈពេលពីរឆ្នាំ បានកែប្រែជីវភាពរបស់នាង វិន រតនា។ គាត់ពុំដែលខ្វល់នឹងការចំអករបស់មិត្តភក្តិខ្លួន អំពីការសិក្សាមេកានិករថយន្តឡើយ។ ក្រោយបញ្ចប់សិក្សាពីសាលាបច្ចេកទេសគាត់បានធ្វើការនៅក្នុងយានដ្ឋានតូចមួយ ទន្ទឹមនឹងការគ្រប់គ្រងដើម្បីសន្សំប្រាក់ សម្រាប់ពង្រឹងការសិក្សារបស់គាត់រហូតដល់ទទួលបានកម្រិតបរិញ្ញាបត្រជាន់ខ្ពស់ខាងការគ្រប់គ្រងធុរកិច្ចកាលពីពីរឆ្នាំកន្លងទៅនេះ។ ឥឡូវនេះ គាត់ គឺជាអ្នកគ្រប់គ្រងយានដ្ឋានទំនើបមួយ ដែលមានជាងបុរសជាអ្នកធ្វើការជួសជុលរថយន្តក្រោមការត្រួតពិនិត្យរបស់គាត់។

នាង វិន រតនា បានពោលថា "បច្ចុប្បន្ននេះ សមត្ថភាពរបស់យុវជនកម្ពុជាដើម្បីប្រកួតប្រជែងនៅមានកម្រិត នៅឡើយ។ នេះជាមូលហេតុដែលយើងត្រូវប្រឹងប្រែងថែមទៀត កុំផ្ដោតទៅរៀនតែមួយមុខដូចជាផ្នែកគណនេយ្យ និងធុរកិច្ចនោះ។ ពួកគេត្រូវតែបង្កើនមុខជំនាញបន្ថែម។ តាមរយៈការធ្វើបែបនេះ យើងសង្ឃឹមថា នឹងកាន់តែមានភាពប្រកួតប្រជែងជាមួយដៃគូរបស់យើងនៅក្នុងអាស៊ាន"។

ចំពោះនាង វិន រតនា នាងកំពុងស្ថិតក្នុងជំហររឹងមាំមួយក្នុងដំណើរឆ្ពោះទៅមុខ ជាមួយទំនុកចិត្ត និងជំនាញចាំបាច់សម្រាប់ប្រកួតប្រជែង។ គេអាចចាត់ទុកបានថា នេះជាភាពជោគជ័យមួយក្នុងចំណោមជោគជ័យបុគ្គលជាច្រើន ដែលអាចធ្វើជាគំរូជួយលើកទឹកចិត្តយុវជនកម្ពុជាដទៃទៀត ក្នុងការស្វែងរកឱកាសការងារ និងកសាងអនាគតឲ្យបានប្រសើរជាងមុន។

Empowered lives.
Resilient nations.

អគារលេខ ៥៣ វិថី ប៉ាស្ទ័រ សង្កាត់ បឹងកេងកង១
ប្រអប់សំបុត្រលេខ ៨៧៧ ក្រុងភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ ៖ +855 (0) 23 216 167
ទូរសារ ៖ +855 (0) 23 216 257
អ៊ីម៉ែល ៖ registry.kh@undp.org
www.kh.undp.org
www.facebook.com/UNDPCambodia
www.twitter.com/UNDPCambodia